# ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

## សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨

សូមគោរព :

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីស្នេហា

មកដល់ពេលនេះ អង្គសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០០៨ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨របស់យើង បានឈានដល់ពេលដែលត្រូវបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អង្គសន្និបាតរបស់យើង បានប្រព្រឹត្តទៅយ៉ាងសកម្ម និងដោយរលូនរហូតដល់ទីបញ្ចប់ដោយជោគជ័យ ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកាទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គសន្និបាតពេលនេះ ពិតជាក្តាប់បានពីសភាពការណ៍រួមនៃសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោកប្រចាំឆមាសទី១ ឆ្នាំ២០០៨ ហើយទន្ទឹមនេះ ក៏បានស្តាប់នូវខ្លឹមសារសំខាន់ៗនៃបទឧទ្ទេសនាម អនុសាសន៍ណែនាំ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវយកទៅអនុវត្តនៅពេលខាងមុខនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ និងលោក លោកស្រី ដែលបានផ្តល់បទឧទ្ទេសនាម និងអនុសាសន៍ណែនាំ ហើយក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិក-សមាជិកានៃអង្គសន្និបាតទាំងអស់ ដែលបានចំណាយពេលដ៏មានតំលៃ មកចូលរួមអង្គសន្និបាតនេះ និងបានខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារនៃបទឧទ្ទេសនាម និងមានវត្តមានក្នុងអង្គសន្និបាតនេះ តាំងពីដើមរហូតដល់ចប់ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

អង្គសន្និបាតរបស់យើងលើកនេះ បានប្រព្រឹត្តទៅរយៈពេលខ្លី ក្នុងរយៈពេលតែមួយថ្ងៃមែន ប៉ុន្តែយើងបានផ្តល់ខ្លឹមសារសំខាន់ៗទាក់ទងនឹងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការពង្រឹងស្ថិរភាពថ្លៃ ការគ្រប់គ្រងអតិផរណា ការងារសវនកម្មផ្ទៃក្នុងនិងអភិបាលកិច្ចល្អ ការពង្រឹងជំនឿទុកចិត្តលើប្រាក់រៀល ការបណ្តុះបណ្តាលធនធានមនុស្សឱ្យវិវឌ្ឍស្របតាមតម្រូវការសេដ្ឋកិច្ច ការត្រួតពិនិត្យប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅ ដោយសុវត្ថិភាព និង

ប្រសិទ្ធភាព ដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីបន្តអនុវត្តទិសដៅការងាររបស់ធនាគារជាតិនៃកម្ពុជា ឱ្យបានជោគជ័យ និងកាន់តែមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមលើកឡើងនូវមតិខ្លះបន្ថែមទៀត ដើម្បីជាការផ្តាំផ្ញើដល់មន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខាខេត្ត-ក្រុង អំពីអ្វីដែលធនាគារជាតិនៃកម្ពុជា ត្រូវធ្វើនៅពេលអនាគត ដូចតទៅ :

**១_ការងារគណនេយ្យ ការងារប្រតិបត្តិការ និងការងារបេឡា**

**ការងារគណនេយ្យ** ជាការងារជំនាញបច្ចេកទេស ទាក់ទងនឹងកិច្ចចុះបញ្ជិកានូវរាល់ប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំឱ្យចេញជារបាយការណ៍ហិរញ្ញវត្ថុមួយ ស្របតាមប្លង់គណនីឯកភាពរបស់ធនាគារជាតិនៃកម្ពុជា ។ ដូច្នេះ សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងមួយចំនួន ដែលមានកង្វះខាតការងាររៀបចំតារាងតុល្យការ ត្រូវខិតខំកែលំអកិច្ចបញ្ជិការបស់ខ្លួនឱ្យកាន់តែសុក្រឹតឡើង ហើយសាខាខេត្ត-ក្រុងណាដែលប្រតិបត្តិបានល្អហើយ ត្រូវបន្តពង្រឹងឱ្យកាន់តែល្អថែមទៀត ។

**ការងារប្រតិបត្តិការធនាគារ** ធនាគារជាតិនៃកម្ពុជា បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងខិតខំកែលំអកន្លែងធ្វើការងារនិងពង្រីកប្រតិបត្តិការសភាផាត់ទាត់នៅតាមតំបន់ ដូចជានៅក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ដែលជាតំបន់មានសក្តានុពលសេដ្ឋកិច្ច ហើយយើងនឹងបន្តធ្វើនៅតាមខេត្តមួយចំនួនទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភ្នាក់ងារសេដ្ឋកិច្ច ។

**ចំពោះការងារបេឡា** ជាការងារបច្ចេកទេសជំនាញទាក់ទង *ទី១*-ការត្រួតពិនិត្យការរាប់ស្រាវជ្រើសប្រភេទរូបិយវត្ថុ និងរូបិយប័ណ្ណតាមការណែនាំ *ទី២*-ការគ្រប់គ្រង និងថែរក្សាសាច់ប្រាក់ឱ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និង*ទី៣*-ការពារសុវត្ថិភាពឃ្លាំងប្រាក់ ។ ការណ៍នេះ អនុវត្តទៅបានប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមន្ត្រីទាំងអស់ប្រកាន់ភ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ មានស្មារតីទទួលខុសត្រូវខ្ពស់ និងគោរពតាមការចាត់តាំង ។

**២_ការពង្រឹងប្រព័ន្ធធនាគារ** ពង្រឹងការអនុវត្តប្រកាសស្តីពីការបង្កើនប្រាក់បម្រុងកាតព្វកិច្ចពី ៨% ទៅ ១៦% ដើម្បីរួមចំណែកអនុវត្តវិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាល និងប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់ឥណទានដើម្បីឱ្យការងារគ្រប់គ្រងឥណទានរបស់ប្រព័ន្ធធនាគារនៅកម្ពុជា កាន់តែមានប្រសិទ្ធភាព និងអាចការពារបាននូវហានិភ័យ ។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS) ក៏ត្រូវពង្រឹងការអនុវត្តដែរ ដើម្បីជួយឱ្យធនាគារនីមួយៗទទួលបានព័ត៌មានជាមូលដ្ឋានច្បាស់លាស់ពីអតិថិជន (KYC) មុននឹងសំរេចចិត្តផ្តល់ឥណទានរបស់ខ្លួន ហើយអាចការពារបាននូវហានិភ័យ អសាធនភាពរបស់អ្នកសុំខ្ចីប្រាក់ និងកាត់បន្ថយឥណទានមិនដំណើរការក្នុងប្រព័ន្ធធនាគារ (NPL) ទៀតផង ។

៣. **វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា** ជាវិស័យដែលមជ្ឈដ្ឋានជាតិនិងអន្តរជាតិចាត់ទុកថា ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។ យើងខិតខំបង្កលក្ខណៈងាយស្រួលតាមផ្លូវច្បាប់ ដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលរឹងមាំ អាចបំពេញលក្ខខណ្ឌដើម្បីអាចទទួលប្រាក់បញ្ញើពីសាធារណជនបាន ស្របតាមតម្រូវការទីផ្សារ និងខិតខំបង្កើតកម្មវិធីផ្សព្វផ្សាយដើម្បីឱ្យប្រជាជនយល់ដឹងពីសារៈប្រយោជន៍នៃការប្រើប្រាស់ឥណទានខ្នាតតូច សំរាប់ជួយកែប្រែជីវភាពប្រជាជននៅជនបទឱ្យមានភាពប្រសើរឡើង ។

៤. **ការងារគ្រប់គ្រងទុនបម្រុង** ធនាគារជាតិនៃកម្ពុជា ត្រូវបន្តគ្រប់គ្រងទុនបម្រុងអន្តរជាតិ ដោយប្រុងប្រយ័ត្នដោយឈរលើគោលការណ៍ សុវត្ថិភាព ចំណូល និងសាច់ប្រាក់ងាយស្រួល ។ ការគ្រប់គ្រងទុនបម្រុង ជាការងារសំខាន់មួយទៀត បន្ថែមលើមុខងាររបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងត្រួតពិនិត្យប្រព័ន្ធធនាគារ ដូច្នេះ ធនាគារកណ្តាល ត្រូវរក្សាបរិមាណទុនបម្រុងរបស់ខ្លួន យ៉ាងតិចឱ្យមានកំរិតស្មើនឹង ៣.៥ ខែនៃការនាំចូលសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រមាណ ២ ខែ សំរាប់ប្រទេសអភិវឌ្ឍន៍ ។

៥. **ការងារស្ថិតិជញ្ជីងទូទាត់** ជាភារកិច្ចស្នូលមួយរបស់ធនាគារជាតិនៃកម្ពុជាដែលមានចែងក្នុងច្បាប់ ហើយមានសារៈសំខាន់ចំពោះវិស័យសេដ្ឋកិច្ចទាំងមូល ។ យើងបន្តបង្កើនប្រសិទ្ធភាព និងគុណភាពស្ថិតិថែមទៀត តាមរយៈការខិតខំសិរិតសំរាំងប្រភពទិន្នន័យ ឱ្យកាន់តែសុក្រឹត និងធ្វើអង្កេតទៅលើប្រភពទិន្នន័យសំខាន់ៗ ព្រមទាំងយកចិត្តទុកដាក់លើការបណ្តុះបណ្តាលមន្ត្រីជំនាញបន្ថែមទៀត ឱ្យឆ្លើយតបទៅនឹងសភាពការណ៍ថ្មីៗ ។ យើងនឹងកែទម្រង់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ ដើម្បីឱ្យស្របតាមសេចក្តីត្រូវការជាក់ស្តែង ។

៦. **ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើង បន្ទាប់ពីច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានអនុម័ត ។ ដើម្បីចូលរួមនិងសហការជាមួយសហគមន៍ជាតិ-អន្តរជាតិ ប្រកបដោយប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលជាឧបករណ៍គតិយុត្តបន្ថែមទៀត សំរាប់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ក្នុងការផ្តល់របាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យទាក់ទងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

៧. **ការងារសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី** ធនាគារជាតិនៃកម្ពុជា នឹងបន្តសហការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលបរទេសក្នុងតំបន់និងពិភពលោក ដើម្បីបណ្តុះបណ្តាល និងធ្វើការស្រាវជ្រាវអំពីដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ។

៨. **ការងារសវនកម្មផ្ទៃក្នុង** ធនាគារជាតិនៃកម្ពុជាខិតខំបន្តពង្រឹងសមត្ថភាពមន្ត្រី *ទី១*-នៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង សំរាប់បំពេញការងារតាមផែនការប្រចាំឆ្នាំដែលបានកំណត់ និង *ទី២*-នៅនាយកដ្ឋានអធិការកិច្ច បំពេញការងារតាមហេតុដែលបានកើតឡើង ។ ដើម្បីដំណើរការងារនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ យើងត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត ឱ្យបានគ្រប់គ្រាន់ស្របទៅតាមតម្រូវការជាក់ស្តែង ។ ឆ្នាំនេះ យើងបានបញ្ជូនមន្ត្រី ២ នាក់ទៅហាត់រៀនការងារជាក់ស្តែងនៅធនាគារកណ្តាលលុចហ្សំបួរ ។

**៩.ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង:** ជាការងារអាទិភាពរបស់យើង ។ យើងត្រូវពង្រឹង និងពង្រីកសកម្មភាពប្រតិបត្តិការសាខាខេត្ត-ក្រុងនៅទូទាំងប្រទេស ដើម្បីជួយសំរួលដល់ការងារចរាចរសាច់ប្រាក់ ការបែងចែកសាច់ប្រាក់ និងគ្រប់គ្រងប្រតិបត្តិការធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ *ជាពិសេស* គឺចូលរួមអនុវត្តន៍កម្មវិធីកំណែទំរង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងការបើកគណនី និងគ្រប់គ្រងសេវាគណនីរបស់រដ្ឋ ចាប់ពីថ្នាក់ឃុំ-សង្កាត់ដល់ថ្នាក់ក្រសួងសំរាប់ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ទូទាត់ពាណិជ្ជកម្ម បង់ពន្ធអាករ និងបើកប្រាក់បៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធទូទាំងប្រទេស ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

**១០. ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្ត្រីបុគ្គលិក** ធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ ការអភិវឌ្ឍន៍ធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា គឺជាការងារដែលត្រូវធ្វើជាប្រចាំនៅទីកន្លែង ។ ការបញ្ជូនទៅចូលរួមវគ្គសិក្សាវែងនិងខ្លីនៅបរទេស ដើម្បីលើកកំពស់សមត្ថភាពមុខជំនាញ ភាសាបរទេស វិន័យការងារ និងស្មារតីទទួលខុសត្រូវខ្ពស់ *ជាពិសេស* ស្វែងយល់ពីបទពិសោធន៍ល្អៗពីប្រទេសដែលមានការអភិវឌ្ឍ ។

**១១.សមាគមមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា** បង្កើតឡើងដើម្បីជួយដោះស្រាយការលំបាករបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ពង្រឹងសាមគ្គីភាពផ្ទៃក្នុងជាភាតរៈភាព និងជួយឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងពេលមានការលំបាក ។ កន្លងមក សមាគមរបស់យើងបានជួយរំលែកការលំបាករបស់មន្ត្រីបុគ្គលិករបស់យើងបានមួយផ្នែក ។ ខ្ញុំសូមឱ្យសមាគមរបស់យើងបន្តយកចិត្តទុកដាក់ការលំបាកលើផ្នែកចាំបាច់ផ្សេងទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា !**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាយើងត្រូវអនុវត្តចំពោះមុខ សំរាប់រយៈពេលខ្លីនិងវែងនាពេលអនាគត ក្នុងគោលដៅបន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធធនាគារទាំងមូលឱ្យកាន់តែមានលក្ខណៈទំនើប និងមានលក្ខណៈសមាហរណកម្មខ្ពស់ មានសុវត្ថិភាព មានប្រសិទ្ធភាព និងទទួលបានការជឿទុកចិត្តពីសាធារណជនជាតិ-អន្តរជាតិ បន្ថែមទៀត ។

ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយឱ្យសំរេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើន ប្រកបដោយចិរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើបីចំណុចដូចខាងក្រោម :

១- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅផ្សព្វផ្សាយបន្ត និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់

២- បន្តបណ្តុះបណ្តាល និងពង្រីកសមត្ថភាពមន្ត្រីបុគ្គលិកទាំងសមត្ថភាពការងារ និងគុណធម៌

៣- បន្តអនុវត្ត " **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥** " ដើម្បីពង្រឹងប្រព័ន្ធធនាគារ ឱ្យកាន់តែមានសុខភាពល្អ ប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មខ្ពស់ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ដែលបានខិតខំរួមចំណែកកសាងសមិទ្ធិផលដ៏ល្អ និងបានកសាងប្រព័ន្ធធនាគារឱ្យទទួលបាននូវជំនឿទុកចិត្តពីសាធារណៈជាតិ និងអន្តរជាតិ កាន់តែប្រសើរឡើង ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាដែលបានអញ្ជើញចូលរួមអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**